**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ០៣ សរណន

## សារាចរណែនាំ

## ស្តីពី

## ការចាត់តាំងខួបអនុស្សាវរីយ៍លើកទី ១៣០ នៃទិវាពលកម្មអន្តរជាតិ ថ្ងៃទី ១ ខែ ឧសភា ឆ្នាំ ២០១៦

ព្រះរាជាណាចក្រកម្ពុជាតែងរៀបចំប្រារព្ធ **ទិវាពលកម្មអន្តរជាតិ ១ ឧសភា** ដែលជាការរំលឹកពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនៃចលនាកម្មករអន្តរជាតិ ដែលទិវានេះត្រូវបានប្រារព្ធឡើងជារៀងរាល់ឆ្នាំចាប់តាំងពីឆ្នាំ ១៩៧៩ មកម្ល៉េះ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលបានកំណត់យក **ថ្ងៃទី ១ ខែ ឧសភា** ជាថ្ងៃបុណ្យការងាររបស់ពលករកម្ពុជា និងជាថ្ងៃឈប់សម្រាករបស់មន្ត្រីរាជការ និងកម្មករនិយោជិតទាំងអស់ ដូចថ្ងៃបុណ្យជាតិ បុណ្យប្រពៃណី និងបុណ្យអន្តរជាតិនានាដែរ ។

**ទិវាពលកម្មអន្តរជាតិ ១ ឧសភា** នាឆ្នាំនេះ ប្រារព្ធឡើងក្រោមប្រធានបទ **«លើកកម្ពស់សេរីភាពអង្គការវិជ្ជាជីវៈ និង ស្ថិរភាពផលិតកម្ម ដើម្បីបង្កើនផលិតភាព និង ការងារ»** សំដៅពង្រឹងភាពសុខដុមរមនាក្នុងទំនាក់ទំនងវិជ្ជាជីវៈ ការធានាបាននូវស្ថិរភាពវិនិយោគ ភាពប្រកួតប្រជែង ការលើកកម្ពស់គុណភាពផលិតផល និងការកែលម្អជីវភាពរបស់កម្មករនិយោជិត ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍប្រទេសជាតិ ។

ដើម្បីរៀបចំការប្រារព្ធ **ខួបអនុស្សាវរីយ៍លើកទី ១៣០ នៃទិវាពលកម្មអន្តរជាតិថ្ងៃទី ១ ខែ ឧសភា ឆ្នាំ ២០១៦** នេះ ឱ្យប្រព្រឹត្តទៅបានល្អប្រសើរថែមទៀត រាជរដ្ឋាភិបាលកម្ពុជាសូមធ្វើការណែនាំដូចខាងក្រោម ÷

***១-*** ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវធ្វើជាស្ថាប័នស្នូលក្នុងការរៀបចំទិវាពលកម្មអន្តរជាតិនេះ ដោយចេញសេចក្តីជូនដំណឹងដល់គ្រប់មន្ទីររាជធានី- ខេត្តក្រោមឱវាទ អង្គការវិជ្ជាជីវៈរបស់និយោជក ម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថាន អង្គការវិជ្ជាជីវៈរបស់កម្មករនិយោជិត ព្រមទាំងកម្មករនិយោជិតទាំងអស់ អំពីការឈប់សម្រាក និងណែនាំលើការរៀបចំកម្មវិធីកំសាន្តសប្បាយនានាតាមលទ្ធភាពរៀងៗខ្លួននៅតាមសហគ្រាស គ្រឹះស្ថាននានា សំដៅបង្កបរិយាកាសស្និទ្ធស្នាល យោគយល់គ្នារវាងកម្មករនិយោជិត និងនិយោជក។ ទន្ទឹមនឹងនេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈត្រូវរៀបចំពិធីមិទ្ទីញថ្នាក់ជាតិ ដែលមានការចូលរួមពីតំណាងក្រសួង ស្ថាប័នរដ្ឋ តំណាងអង្គការវិជ្ជាជីវៈ តំណាងអង្គការជាតិ និងអន្តរជាតិដែលជាដៃគូ ។ ដោយឡែក គ្រប់រាជធានី ខេត្តទាំងអស់ត្រូវចាត់តាំងរៀបចំពិធីសំណេះសំណាលជាមួយតំណាងកម្មករនិយោជិតនៅតាមបណ្តារោងចក្រ សហគ្រាស គ្រឹះស្ថានតាមស្ថានភាពជាក់ស្តែង ។

**២-** ក្រសួងមហាផ្ទៃ អគ្គស្នងការដ្ឋាននគរបាលជាតិ បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស អាជ្ញាធរដែនដីរាជធានី ខេត្ត និងស្ថាប័នពាក់ព័ន្ធទាំងអស់ត្រូវមានវិធានការតាមសមត្ថកិច្ចរៀងៗខ្លួន ក្នុងការថែរក្សាការពារសន្តិសុខ សុវត្ថិភាព សណ្ដាប់ធ្នាប់សាធារណៈ ក្នុងឱកាសនៃការប្រារព្ធ**ទិវាពលកម្មអន្តរជាតិ ១ ឧសភា ២០១៦** នេះ ។

**៣-** ក្រសួងព័ត៌មានត្រូវណែនាំប្រព័ន្ធឃោសនារបស់រដ្ឋ និងឯកជនឱ្យធ្វើការផ្សព្វផ្សាយសារលិខិតរបស់នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាស**ខួបអនុស្សាវរីយ៍លើកទី ១៣០ នៃទិវាពលកម្មអន្តរជាតិ ១ ឧសភា** និងចាក់ផ្សាយសកម្មភាពមិទ្ទីញ ការកំសាន្តសប្បាយនានារបស់កម្មករនិយោជិត និយោជកនៅតាមសហគ្រាស និងគ្រឹះស្ថាននានា ។

**៤-** ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវបង្កលក្ខណៈងាយស្រួល ក្នុងការបើកផ្ដល់ថវិកាប្រើប្រាស់សម្រាប់ការរៀបចំប្រារព្ធ**ទិវាពលកម្មអន្តរជាតិ ១ ឧសភា** នេះ ។

**៥-** រាជធានីភ្នំពេញ និងខេត្តទាំងអស់ ក៏ដូចជាក្រសួង ស្ថាប័ន អង្គភាពរដ្ឋ និងសហគ្រាស គ្រឹះស្ថានឯកជនត្រូវជ្រើសរើសទីតាំងសមស្រប រួមមានផងវិថីសំខាន់ៗ និងទីតាំងសហគ្រាស គ្រឹះស្ថាន ការដ្ឋាន និងកសិដ្ឋាន ដើម្បីធ្វើការចងបដាពាក្យស្លោកតាមខ្លឹមសារដូចខាងក្រោម ÷

- ជយោ ! ព្រះរាជាណាចក្រកម្ពុជា
- អបអរសាទរខួបអនុស្សាវរីយ៍លើកទី ១៣០ នៃទិវាពលកម្មអន្តរជាតិ ១ ឧសភា
- លើកកម្ពស់សេរីភាពអង្គការវិជ្ជាជីវៈ និងស្ថិរភាពផលិតកម្ម ដើម្បីបង្កើនផលិតភាព និងការងារ
- ខិតខំកសាងភាពសុខដុមរមនារវាងនិយោជក និងកម្មករនិយោជិតនៅតាមសហគ្រាស និងគ្រឹះស្ថាន ។

រាជរដ្ឋាភិបាលកម្ពុជា សូមអំពាវនាវដល់មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ និយោជក កម្មករនិយោជិតកម្ពុជា និងពលករបរទេសទាំងអស់ចូលរួមប្រារព្ធ និងអបអរសាទរ**ទិវាពលកម្មអន្តរជាតិ ១ ឧសភា** ក្នុងបរិយាកាសរីករាយ សាមគ្គីភាព និងភាតរភាពឱ្យស័ក្តិសមជាបុណ្យការងាររបស់ប្រទេសជាតិយើង ។

ទទួលបានសារាចរណែនាំនេះ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដីរាជធានីខេត្តត្រូវរៀបចំចាត់តាំងអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវ និងមានប្រសិទ្ធភាពខ្ពស់ ។

*រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៦*

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល÷**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *គ្រប់ក្រសួង ស្ថាប័ន*
- *ខុទ្ទកាល័យ សម្ដេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *សាលារាជធានី ខេត្ត*
- *រាជកិច្ច*
- *ឯកសារ- កាលប្បវត្តិ*